ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សភាផ្នែករដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណី
លេខ : ១៥៦
ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧

សាលដីកា

លេខ : ១៥១
ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៨

ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៨ ដោយមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម តិត មន្នី ជាប្រធាន
២- លោក ម៉ែន ស៊ិន ជាចៅក្រម
៣- លោក ទេវុល មួន ជាចៅក្រម
៤- លោក ស៊ិន តឹម ជាចៅក្រម
៥- លោក ជីវ រកង ជាចៅក្រម

ក្រឡាបញ្ជី
កញ្ញា សេន សុខា
តំណាងមហាអយ្យការ
លោក ជួន ស៊ិនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ១០៨ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២២ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ កាំង ហន អាយុ៥៣ឆ្នាំ ជាតិខ្មែរ ភេទស្រី មុខរបរធ្វើស្រែ ទីលំនៅ ភូមិតាកុក២ ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ យង់ កាំង "ស" ម្តាយឈ្មោះ ស៊ីង តឹម "ស" ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ កាំង ហ៊ិន អាយុ៤៦ឆ្នាំ ជាតិខ្មែរ ភេទស្រី មុខរបរធ្វើស្រែ ទីលំនៅភូមិតាកុក១ ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ យង់ កាំង "ស" ម្តាយឈ្មោះ ស៊ីង តឹម "ស" ។

កម្មវត្ថុបណ្តឹង : ប្តឹងសុំចែកមរតកផ្ទះព្រាយ និង ដីស្រែស្រូវ

តាមបណ្តឹងសាទុក្ខលេខ ១៨ ចុះថ្ងៃទី ១១ ខែមិនា ឆ្នាំ១៩៩៧ របស់ឈ្មោះ កាំង ហន បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីកាលេខ ១០៨ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ខាងលើ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៥៦ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧ របស់

។.

តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៨.៥.៨៤ របស់ឈ្មោះ កាំង ហ៊ិន ប្តឹងទាមទារអោយរុះរើផ្ទះញយ និង ជង្រុកស្រូវដែលចែកគ្នាជា២ចំណែកស្មើគ្នា ដោយសំអាងហេតុថា ផ្ទះញយ និង ជង្រុកស្រូវនេះជាមរតករបស់ឪពុក ម្តាយ ពួកខ្លួនទាំងពីរ ។ កាលពីឆ្នាំ ១៩៧៩ ខ្លួន និងបងស្រីឈ្មោះ កាំង ហន ចូលមកកាន់កាប់គ្រប់គ្រងរួមគ្នា ។

បានឃើញសាលក្រមលេខ ២៧៤ ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ១៩៨៥ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារដូចតទៅ :

១-ក. ទទួលពាក្យបណ្តឹងចុះថ្ងៃទី ០៨.៥.១៩៨៤ របស់ដើមចោទឈ្មោះ កាំង ហ៊ិន ប្តឹងទាមទារផ្ទះញយ និង ជង្រុកស្រូវពីឈ្មោះ កាំង ហន ជាចុងចម្លើយទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

ខ. ទទួលយកសំណូមពរនាពេលសវនាការរបស់ដើមចោទឈ្មោះ កាំង ហ៊ិន សុំថ្លៃកំណល់ដើមឈើ និង សុំចេញថ្លៃជង្រុកស្រូវជាចំណែកខាងចុងចម្លើយឈ្មោះ កាំង ហន ទុកជាត្រឹមត្រូវតាមគតិច្បាប់ ។

គ. បដិសេធចោលសំណូមពរនាពេលសវនាការរបស់ចុងចម្លើយឈ្មោះ កាំង ហន សុំសិទ្ធិគ្រប់គ្រងកំណល់ដើមឈើ និង សុំកាត់ជង្រុកស្រូវជា២ចំណែកដោយផ្អែកលើគតិច្បាប់ ។ តែទទួលយកសំណូមពរដោយសុំប្រគល់ដល់ដើមចោទនូវផ្ទះញយ និង ជង្រុកស្រូវនេះ ដោយចេញថ្លៃឲ្យកនអោយខ្លួនទុកជាត្រឹមត្រូវតាមគតិច្បាប់ ។

២- ប្រគល់ជាកម្មសិទ្ធិនូវផ្ទះញយ និង ជង្រុកស្រូវទាំងស្រុងអោយដល់ដើមចោទឈ្មោះ កាំង ហ៊ិន តែអោយដើមចោទចេញតំលៃផ្ទះញយ និង ជង្រុកស្រូវគិតសរុបជាប្រាក់រៀលស្មើនឹងមាសទឹកដប់ចំនួន ៥ជី "ប្រាំជី" អោយដល់ចុងចម្លើយឈ្មោះ កាំង ហន គិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

៣- ប្រគល់កំណល់ដើមឈើជាកម្មសិទ្ធិអោយដល់ចុងចម្លើយឈ្មោះ កាំង ហន តែអោយឈ្មោះ កាំង ហន ចេញថ្លៃកំណល់ដើមឈើគិតជាប្រាក់រៀលស្មើនឹងមាសទឹកដប់ចំនួន១ជី "មួយជី" អោយដល់ឈ្មោះ កាំង ហ៊ិន ជាដើមចោទ គិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

៤- អោយឈ្មោះ កាំង ហ៊ិន ជាដើមចោទ ជាម្ចាស់កម្មសិទ្ធិករលើចលនវត្ថុគឺ ជង្រុកស្រូវ និងផ្ទះញយដោយត្រូវរុះរើចេញពីដីកម្មសិទ្ធិកររបស់ឈ្មោះ កាំង ហន ជាចុងចម្លើយ គិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

តាមមាត្រា ៣៦ , ៣៧ , ៤០ និង ៤១ នៃច្បាប់ភូមិបាលដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១០០ក្រ ចុះថ្ងៃទី ១៣.១០.៨២ ។

៥- អោយចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី : ពន្ធចុះបញ្ជីក្តី និង ពន្ធតែម ១.៨០០៛

រង្វាន់ក្រមស្រាបញ្ញាកាន់ហិបប្រាក់ ២០០៛ រង្វាន់ប្រគល់ដីការកោះ ២.០០០៛ ចំណាយអង្កេត រំលឹបប្ដូរ ៣.០០០៛ សរុប ៦.០០០៛ ។
ប្រាក់នេះបានកាត់យកពីប្រាក់ចំនួន ៦.០០០៛ ដែលដើមចោទបានបង់រួចហើយ កាលបើជំនុំ ឧទ្ធរណ៍អោយចុងចម្លើយសងប្រាក់ ៦.០០០៛ ដល់ដើមចោទវិញ និងអោយបង់ពន្ធមហាក្រុ ចំនួន ៥.០០០៛ ប្រាក់នេះបង់ចូលថវិការដ្ឋ ៨០ភាគរយ និង ២០ភាគរយ ដាក់ចូលហិបប្រាក់ ក្រមស្រាបញ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជា ។

តាមច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃ- ទី ០៨.០២.៥៣ ។

៦- សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី ។

បើកផ្លូវឧទ្ធរណ៍កំណត់ ២ខែ គិតពីថ្ងៃកាត់ក្ដីតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១៥.១២.៨៥ របស់ឈ្មោះ កាំង ហន ដែលប្ដឹងជំទាស់នឹង សាលក្រមរដ្ឋប្បវេណីលេខ ២៦៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៨៥ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចទី១ និង ទី៣នៃសេចក្ដីសំរេច ។

បានឃើញសាលដីការលេខ ១០៨ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ១៩៨៦ របស់សាលា ឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១៥.១២.១៩៨៥ របស់ឈ្មោះ កាំង ហន ទុកជា ត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលព្រោះទាស់មុខនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២៦៤ ចុះថ្ងៃទី០២.១២.១៩៨៥ របស់តុលាការ ខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣- សំរេចកាត់យកប្រាក់ប្រដាប់ក្ដីនៅថ្នាក់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលដើម បណ្ដឹងឧទ្ធរណ៍បានបង់មុនរួចហើយពី ពន្ធចុះបញ្ជីក្ដី និង ពន្ធតែម ២.៥៥០៛ រង្វាន់ក្រមស្រាបញ្ញាកាន់ ហិបប្រាក់ ២៥០៛ ចំណាយលើការប្រគល់ដីការកោះ ៥.០០០៛ និង អាជ្ញាធរតុលាការ ៥.០០០៛ ។

៤- សាលដីការនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី ។ សំរេចបើក ផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៦៨ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ១៩៨៦ របស់ឈ្មោះ- កាំង ហន ប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៨៦ របស់ឈ្មោះ កាំង ហន ។

បានឃើញសារណាតបចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៨៦ របស់ឈ្មោះ កាំង ប៊ុន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា ៖ តុលាការកំពូលគប្បីតម្កល់សាលដីកាឧទ្ធរណ៍លេខ ១០៨ ចុះថ្ងៃទី ១១.៣.៩១ របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

ហេតុដូចនេះ សូមក្រុមប្រឹក្សាជំនុំជំរះពិនិត្យពិចារណានិងសំរេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះ កាំង ហន ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខ បានឆ្លើយនៅពេលសវនាការថា ៖ ជង្រុកស្រូវខ្លួនបានចែកគ្នារួចហើយ ខ្លួនគ្មានអ្វីចែកទៀតទេ ចំពោះដីធ្លីខ្លួនមិនលក់ទេ ទោះតថ្លៃប៉ុន្មានក៏ដោយ ហើយខ្លួនគ្មានផ្ទះនៅភូមិដើមដូងមកចែកអោយទៀតទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ កាំង ហ៊ុន ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខបានឆ្លើយនៅពេលសវនាការថា ៖ ចំពោះបញ្ហាដីធ្លីចែកគ្នាមិនដាច់ពេលនោះគឺលក់តថ្លៃ ២.០០០៛ ពេលខ្លួនអោយលុយគ្រប់ហើយ ហើយខ្លួនទៅគាស់ដីធ្លីគាត់មិនព្រម បញ្ហាជង្រុកស្រូវគាត់ថាលុះត្រាតែពុះហើយចែកគ្នាជាពីរ លុះក្រោយមកទៀតគាត់ថាបើយកលុយលុះត្រាតែ ៤ជី ពេលខ្លួនយកលុយអោយគាត់បែរជាប្តឹងទៅវិញ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>តុលាការកំពូល</u>

- យល់ឃើញថា ៖ បណ្តឹងសាទុក្ខលេខ ៦៨ ចុះថ្ងៃទី ១១.៣.៩១ របស់អ្នកស្រី កាន់ ហន ធ្វើទៀងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ៖ មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដើមចោទ និងចុងចម្លើយពិតជាបានកាន់កាប់ និង គ្រប់គ្រងជង្រុកស្រូវ ផ្ទះឡាយ និង កំណល់ដីធ្លីជាមរតកពីសង្គមមុន ចាប់ពីក្រោយថ្ងៃរំដោះឆ្នាំ ១៩៧៩ ឬ ១៩៨៣ ពិតប្រាកដមែន ។

- យល់ឃើញថា ៖ ដើមចោទ និង ចុងចម្លើយជាបងប្អូនបង្កើតនឹងគ្នា ហើយបានឯកភាពគ្នារៀបចំចែកផ្ទះធំរួចអស់ហើយ នៅសល់តែជង្រុកស្រូវ ផ្ទះឡាយ និង កំណល់ដីធ្លីតែប៉ុណ្ណោះដែលគូភាគីពុំទាន់បានចែកគ្នានៅឡើយ ។

- យល់ឃើញថា ៖ ការសុំរៀបចំចែកទ្រព្យសម្បត្តិជាសហកម្មសិទ្ធិរបស់ដើមចោទនេះ ចុងចម្លើយក៏បានឯកភាពប្រគល់ជង្រុកស្រូវអោយទៅដើមចោទផងដែរ ដោយចុងចម្លើយយល់ថា ប្អូនខ្លួនមានកូនច្រើន ដូច្នេះការដែលតុលាការថ្នាក់ក្រោមគឺ ដូចសាលាឧទ្ធរណ៍ដែល

ដែលសំរេចប្រគល់ជង្រុកស្រូវជាចំណែករបស់ចុងចម្លើយអោយទៅដើមចោទ ដោយអោយដើម-ចោទចេញតម្លៃសមស្របអោយទៅចុងចម្លើយ ក៏ដូចជាការប្រគល់កំណាត់ដីដែលដំឡើងអោយទៅចុងចម្លើយ ហើយអោយចុងចម្លើយចេញថ្លៃដីសមស្របទៅអោយដើមចោទវិញ និង អោយដើមចោទរុះរើជង្រុកស្រូវ និង ផ្ទះបាយចេញពីដីចុងចម្លើយនោះជាការសមរម្យហើយ ។

- យល់ឃើញថា : ខ្លឹមសារនៃសារណារបស់ភាគី តុលាការថ្នាក់ក្រោមបានពិចារណាសព្វគ្រប់ហើយ ។

- យល់ឃើញថា : សាលដីកាឧទ្ធរណ៍លេខ ១០៥ ចុះថ្ងៃទី ១១.៣.៩៦ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ៧៨ ចុះថ្ងៃទី ១១ ខែមិនា ឆ្នាំ១៩៩៦ របស់អ្នកស្រី-ការ៉ំ ចន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាឧទ្ធរណ៍លេខ ១០៥ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៦ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣- ឲ្យបង្វិលប្រាក់ប្រដាប់ក្តីដែលអ្នកស្រី ការ៉ន ចន បានបង់ទុកនៅតុលាការកំពូលចំនួន-១៩.០០០ រៀល គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធតែមចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់បញ្ជីប្រាក់ ,
- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប - ១៩.០០០រៀល

បង្គាប់អោយចុងចម្លើយបង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តបាត់ដំបង ។

៤- សាលដីកានេះប្រកាសនាសវនាការជំរះជាសាធារណៈ នៅថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៩៨ ។